# របាយការណ៍មហាសារៈ

# ក.ស.ឯ

## អារម្ភកថា៖

ដោយបញ្ហាផែនទីកំពុងក្លាយជាល្បែងនយោបាយពេញនិយមរបស់គណបក្សនយោបាយធំៗទាំងពីរ នៅពេលដែលពលរដ្ឋរស់នៅតាមបណ្តោយព្រំដែនកំពុងប្រឈមនឹងការទន្ទ្រានយកដីពីប្រទេសជិតខាងយ៉ាងគឃ្លើន ក.ស.ឯ ដែលជាក្រុមស្រាវជ្រាវឯករាជខ្មែរឯនាយសមុទ្រ បានសិក្សាស្រាវជ្រាវលើផែនទីផ្សេងៗចំនួន ៣៨៦ផ្ទាំង ដើម្បីផ្តល់ចម្លើយនិងការបកស្រាយបំភ្លឺជុំវិញចម្ងល់របស់ពលរដ្ឋខ្មែរដែលកំពុងរងគ្រោះ។ យើងសូមបញ្ជាក់ថា នេះគឺជាការសិក្សាជំហានដំបូងដ៏មានសារៈសំខាន់ដើម្បីត្រួសត្រាយផ្លូវទៅរកការសិក្សាលំអិតដ៏ទៃទៀត ចំពោះបញ្ហាទាំងឡាយដែលចោទឡើងដោយការសិក្សាស្រាវជ្រាវនេះ។ ដូច្នេះការសិក្សាលំអិតលើចំណុចនិមួយៗទាមទារក្រុមឯកទេសជាច្រើនទៀត។

## របាយការណ៍នៃការសិក្សាបឋមរបស់ក្រុមស្រាវជ្រាវឯករាជ(ក.ស.ឯ.)

ការសិក្សាបឋមរបស់ក.ស.ឯ លើផែនទីខាងក្រោម៖

- ផែនទីបោនមាត្រដ្ឋាន១/១០០,០០០ ១១៩ផ្ទាំង ដែលផលិតនិងបោះពុម្ពនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ (យូរបំផុតនៅឆ្នាំ១៩៥៤)ដោយសេវាភូមិសាស្រ្តឥណ្ឌូចិន ហើយត្រូវបានគេយកទៅតំកល់ទុកនៅវិទ្យាស្ថានភូមិសាស្រ្តជាតិបារាំងនៅឆ្នាំផ្សេងៗគ្នា...

- ផែនទីមាត្រដ្ឋានបោន១/១០០,០០០ ១២៦ផ្ទាំង ផ្តល់ដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង។ ជាផែនទីផលិតនិងបោះពុម្ពដោយសេវាភូមិសាស្រ្តឥណ្ឌូចិននៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ និង១៩៥៤

- ផែនទីមាត្រដ្ឋាន១/១០០,០០០ ចំនួន៤៩ផ្ទាំងផ្តល់ដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង៖ មានផែនទីបោនមាត្រដ្ឋាន១/១០០,០០០ ចំនួន២០ផ្ទាំង ផលិតនិងបោះពុម្ពដោយសេវាភូមិសាស្រ្តឥណ្ឌូចិននៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ និង១៩៥៤ និង ផែនទីមាត្រដ្ឋាន១/១០០,០០០ ធម្មតាចំនួន២៩ផ្ទាំង ផលិតនិងបោះពុម្ពដោយក្រុមអានាមិកនោះចន្លោះឆ្នាំ១៩៧៧-១៩៨៨ យកទៅតំកល់នៅទុកនៅវិទ្យាស្ថានភូមិសាស្រ្តជាតិបារាំងនៅឆ្នាំ១៩៩៣-១៩៩៤

- ២៦ផ្ទាំងដែលគណបក្សសង្គ្រោះជាតិ និងស្ថានទូតបារាំងយកទៅប្រគល់អោយរដ្ឋាភិបាលភ្នំពេញធ្វើការផ្ទៀងផ្ទាត់ជាមួយផែនទីរបស់រដ្ឋាភិបាលភ្នំពេញកាលពីខែកក្កដានិងដើមខែកញ្ញា២០១៥


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

- ផែនទីយោធាអាមេរិកទាំង៤០ផ្ទាំង មាត្រដ្ឋាន១/៥០,០០០ ដែលភ្នំពេញនិងហាណូយយកធ្វើជាមូលដ្ឋានបោះបង្គោលព្រំដែនរវាងកម្ពុជានិងយួន

ការសិក្សាបឋមនៃផែនទីទាំងនេះបានទទួលលទ្ធផលដូចខាងក្រោម៖

## ១/ផែនទី១១៩ផ្ទាំងរបស់សេវាភូមិសាស្ត្រឥណ្ឌូចិនដែលត្រូវបានគេយកទៅតំកល់ទុកនៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងនៅឆ្នាំ ១៩៦២ ១៩៦៣ ១៩៦៤ និង១៩៨៣

ផែនទីទាំង**១១៩**ផ្ទាំង មាត្រដ្ឋាន១/១០០,០០០ ដែលមានចារថា ផលិតដោយសេវាភូមិសាស្ត្រឥណ្ឌូចិន ហើយដែលត្រូវបានគេយកទៅតំកល់ទុកនៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងនៅឆ្នាំ**១៩៦២ ១៩៦៣ ១៩៦៤** និង **១៩៨៣** ភាគច្រើនសុទ្ធសឹងផលិតនិងបោះពុម្ពនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ក្នុងនោះមានតែ១៣ផ្ទាំងទេដែលផលិតនៅឆ្នាំ១៩៥៤ និង ១ផ្ទាំងផលិតនៅឆ្នាំ១៩៥៥ ដែលមានលេខកូដដូចខាងក្រោម៖

| | | | |
|---|---|---|---|
| Attopeu147W54 | Klong-klun195E54 | Ream225E54 | Tropeang-kroleng207E54 |
| Chamnop200E54 | Kompong-som216E54 | Ream225W54 | Tropeang-kroleng207W54 |
| Chamnop200W54 | Kompong-som216W54 | Tang-phloch197E54 | |
| Kas-moul205-54 | | Tang-phloch197W54 | Phiafay146E55 |

### ១-១ ការសិក្សាអំពីត្រាដែលបោះលើផែនទីទាំង១១៩

ការសិក្សាបឋមលើត្រាដែលបោះលើផែនទីបានមាត្រដ្ឋាន១/១០០.០០០ទាំង**១១៩**ផ្ទាំង បានអោយឃើញថា ផែនទីចំនួន**៧៣**ផ្ទាំង មានបោះត្រាកំណត់កាលបរិច្ឆេទយកទៅតំកល់នៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងយ៉ាងត្រឹមត្រូវ៖ ផែនទីចំនួន **៦៩**ផ្ទាំង មានបោះត្រាតំកល់ថ្ងៃទី**៥ ខែធ្នូ ឆ្នាំ១៩៦៣** ដែលយើងគិតថា ជាផែនទីពិតរបស់ខ្មែរដែលសម្តេច ស៊ីហនុ តែងបាននិយាយថា បានយកទៅតំកល់នៅអង្គការសហប្រជាជាតិ និង **៤ផ្ទាំង** មានបោះត្រាតំកល់ **ថ្ងៃទី១៦ ខែមិថុនា ១៩៦៤** ទាក់ទងនឹងខេត្តខុង(154E-64) សៀមរាប(167bisW-52) ខេត្តរៀនស (155W) និងខេត្តយ៉ាលី(156W-55) ដែលជាប្រភេទផែនទីយោធា។ ឯផែនទី៤៦ផ្ទាំងទៀត៖ មាន៣១ផ្ទាំងបោះនឹងត្រាចម្លែក គ្មានកំណត់កាលបរិច្ឆេទត្រាតំកល់ ៥ផ្ទាំងបោះនឹងត្រាចម្លែកដូចគ្នានិងមានបោះត្រាកំណត់កាលបរិច្ឆេទឆ្នាំខុសៗគ្នា ហើយផែនទី១០ផ្ទាំងផ្សេងទៀតនៃផែនទី៤៦ គឺគ្មានត្រាតែម្តង។ ផែនទីទាំងនេះសុទ្ធសឹងតែជាផែនទីជាប់នឹងព្រំប្រទល់ប្រទេសជិតខាង។

### ១-២ ត្រាវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងបោះលើផែនទីបាន ទាំង៦៩ផ្ទាំង និងផែនទីយោធា ទាំង៤

(៦៩ផ្ទាំង៖៥ធ្នូ១៩៦៣ - ៤ផ្ទាំង៖ ១៦ មិថុនា ១៩៦៤)- គឺជាត្រាមានរង្វង់ពងក្រពើផ្តេក មានសរសេរ Institut


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

Géographique National នៅផ្នែកខាងលើ ដែលត្រូវបានសរសេរជាអក្សរធំនៅដើមពាក្យនិមួយៗ។ នៅផ្នែកខាងក្រោមមានសរសេរ Cartothèque ជាអក្សរធំ។ នៅកណ្ដាលរង្វង់ត្រាមានគូសចតុកោណកែងមួយ ជាកន្លែងសម្រាប់ចារកាលបរិច្ឆេទត្រាបោះលើឯកសារនិមួយៗដែលគេយកទៅតំកល់នៅវិទ្យាស្ថាន ដូចរូបខាងក្រោមនេះ៖




## ១-៣ ការសិក្សាអំពីផែនទីទាំង៤៦ផ្ទាំងដែលគ្មានត្រានិងមានបោះត្រាចម្លែក

ក្នុងចំណោមផែនទី៤៦ **មានផែនទី**១០ផ្ទាំងគ្មានស្រមោលត្រាអ្វីទាំងអស់ ចំណែកឯផែនទី៣៦ផ្ទាំងទៀតសុទ្ធតែបោះនឹងត្រាចម្លែក ដែល៣១ផ្ទាំងបោះនឹងត្រាគ្មានកាលបរិច្ឆេទតំកល់ទេ និង៥ផ្ទាំងបោះនឹងត្រាចម្លែកដែល


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

មានចារកាលបរិច្ឆេទតំកល់ផ្សេងៗគ្នា គឺ ៣ផ្ទាំងមានបោះត្រាកាលបរិច្ឆេទ ថ្ងៃទី ២៩មិនា១៩៦២ ទាក់ទងនឹងខេត្តបន្ទាយស្រី(159bisE-51-62) ខេត្តក្រលាញ់(159W-52-62) និងស៊ីសុផុន (158bisE-51-62)។ ១ផ្ទាំងបោះត្រាកាលបរិច្ឆេទ ថ្ងៃទី២២ ឆ្នាំ១៩៦៣ ទាក់ទងនឹងខេត្តហ្វីយ៉ាហ្វាយ(146E-55-63) និង១ផ្ទាំងទៀតបោះត្រាកាលបរិច្ឆេទតំកល់ ថ្ងៃទី ១០ សីហា ឆ្នាំ១៩៨៣ ទាក់ទងនឹងខេត្តស្វាយរៀង(219W-51-83)។

ត្រាចម្លែកឬក្លែងក្លាយដែលបោះលើផែនទីទាំង៣៦ផ្ទាំង មានចំណុចជាច្រើនខុសពីត្រាបោះលើផែនទីទាំង៧៣ (៦៩ផ្ទាំង ៥ធ្នូ១៩៦៣ និង ៤ផ្ទាំងជាផែនទីយោធា ១៦មិថុនា១៩៦៤) ជាត្រាមានរាងពងក្រពើផ្តេកស្រដៀងនឹងត្រាបោះលើផែនទីទាំង៧៣ដែរ តែមានរាងតូចជាងនិងគ្មានរូបចតុកោណកែងនៅកណ្តាលសម្រាប់ចារកាលបរិច្ឆេទតំកល់ឯកសារទេ មានតែខ្សែបន្ទាត់ត្រង់ពីរជាប់ជាមួយខ្សែរង្វង់ត្រាពីចុងម្ខាងទៅចុងម្ខាង។

ផែនទីទាំង៤៦ផ្ទាំងដែលគ្មានត្រាឬមានត្រាចម្លែកទាំងនោះ ទោះមានបោះកាលបរិច្ឆេទតំកល់ឬគ្មានក្តី សុទ្ធតែមានចារថា ជាផែនទីផលិតដោយសេវាភូមិសាស្រ្តឥណ្ឌូចិននៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ និងមួយចំនួនតូចនៅឆ្នាំ ១៩៥៤ (៦ផ្ទាំង) ១ផ្ទាំងនៅឆ្នាំ១៩៥៥។ ផែនទីទាំង ៤៦ ដែលគ្មានត្រាឬបោះនឹងត្រាចម្លែក និងផែនទីយោធាអាមេរិក៤ផ្ទាំងទៀត អាចជាផែនទីគេយកទៅជំនួសផែនទីពិត ដែលត្រូវបានយកទៅតំកល់នៅវិទ្យាស្ថានភូមិសាស្រ្តជាតិបារាំងនៅថ្ងៃទី៥ធ្នូ១៩៦៣ ដូច្នេះកម្ពុជាមិនត្រឹមតែត្រូវបាត់បង់ផែនទី៥០ផ្ទាំង(៤៦ផ្ទាំងផែនទីបោន និង៤ផ្ទាំងផែនទីយោធា) ដែលបារាំងគូសអោយនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានយកទៅតំកល់នៅវិទ្យាស្ថានភូមិសាស្រ្តជាតិបារាំងនៅថ្ងៃទី ៥ធ្នូ១៩៦៣ទេ តែក៏ត្រូវបាត់បង់ទឹកដី ហើយពលរដ្ឋរស់នៅតាមបណ្តោយព្រំដែនត្រូវរងទុក្ខវេទនាដោយសារការប្រើប្រាស់ផែនទីមិនច្បាស់លាស់ឬក្លែងក្លាយសម្រាប់កំណត់ព្រំដែនកម្ពុជា-យួន។

ផែនទីដែលបាត់បង់ទាំងនោះប្រហែលជាត្រូវបានគេលួចយកទៅលាក់ទុកឬបំផ្លាញចោល ហើយជំនួសដោយផែនទីក្លែងក្លាយទាំង៤៦ផ្ទាំងនិងផែនទីយោធា៤ផ្ទាំង។ ក្នុងករណីដែលគេសន្មតថា ផែនទីមានត្រាត្រឹមត្រូវដូចគ្នានឹងផែនទីដែលមានត្រាចម្លែក នោះគេមិនចាំបាច់ខំប្រឹងប្រែងលួចបន្លំប្តូរផែនទីទេ ព្រោះមិនមែនជាការងាយឡើយក្នុងបេសកម្មប្តូរបន្លំផែនទីពិត ហើយជំនួសដោយផែនទីក្លែងក្លាយឬផែនទីទើបនឹងគូសថ្មីៗ នៅតាមវិទ្យាស្ថានអន្តរជាតិនានា។ ដូច្នេះកម្ពុជាចាំបាច់ត្រូវតែស្វែងរកផែនទីទាំង៥០ផ្ទាំងដែលបាត់បង់មុននឹងកំណត់ព្រំដែនជាមួយប្រទេសជិតខាង។

ផែនទីក្លែងក្លាយដែលត្រូវបានគេយកទៅដាក់លាយឡំជាមួយផែនទីពិត បញ្ជាក់ពីទេពកោសល្យនៃជនឬក្រុមបន្លំទាំងនោះ ដូចជាក្នុងចំណោមផែនទី២ផ្ទាំងក្នុងខេត្តតែមួយ គេឃើញមានលាយផែនទីមានត្រាចម្លែកមួយផ្ទាំងព្រោះអាចជាតំបន់ដែលមានការសើរើខ្សែបន្ទាត់ព្រំដែន ឯកន្លែងដែលគ្មានការរំកិលដីឬប្តូរបន្ទាត់ព្រំដែន គេរក្សាទុកផែនទីដើមដែលមានកំណត់កាលបរិច្ឆេទត្រឹមត្រូវ(៥ធ្នូ១៩៦៣) ដូចជាចំពោះ ខេត្តតាកែវ ផែនទីលេខ ២១៨E ជាផែនទីដែលអាចជាផែនទីក្លែងក្លាយព្រោះជាផែនទីបោះត្រាចម្លែក និងផែនទីលេខ២១៨W ជាផែនទីពិត ព្រោះត្រាដែលបោះលើផែនទីនេះមានចារកាលបរិច្ឆេទត្រាតំកល់ច្បាស់លាស់(៥ធ្នូ១៩៦៣)។ ផែនទីខេត្តព្រៃវែងលេខ


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

២០៩ ក៏ដូច្នោះដែរ គឺ២០៩E ជាផែនទីក្លែងក្លាយ និង២០៩W ជាផែនទីពិត។ល។ ដោយហេតុផលដូចបានជម្រាប។

ចំពោះខេត្តខ្លះ ផែនទីទាំងពីរផ្ទាំង(ខាងលិចតំណាងដោយអក្សរ W និងខាងកើតតំណាងដោយអក្សរ E) សុទ្ធតែមានបោះត្រាចម្លែកទាំងពីរតែម្តង ដូចជាខេត្តត្រាំងបាំង (220E និង 220E) មេមុត(200E និង 200W) ហាទៀង( 227E និង 227W) ស្វាយរៀង (219E និង 219W) លុកនិញ(201E និង 201W) បានដុង(181E និង181W) ។ល។ គួរកត់សំគាល់ផងដែរថា អោយតែផែនទីជាប់ប្រទេសជិតខាង មានប្រទេសថៃ ប្រទេសលាវ (មួយចំនួនតូច) និងជាពិសេសផែនទីជាប់ព្រំប្រទល់ជាមួយប្រទេសយួន សុទ្ធតែនៅក្នុងក្រុមផែនទីដែលមានបោះត្រាចម្លែកឬក៏គ្មានត្រាតែម្តង។

**១-៤ ត្រាចម្លែកឬក្លែងក្លាយបោះលើផែនទីទាំង៣៦** - គឺជាត្រាមានទម្រង់ពងក្រពើផ្តេកដែរ មានសរសេរ Institut Géographique National នៅផ្នែកខាងលើ និងផ្នែកខាងក្រោមមានសរសេរ Cartothèque តែត្រូវបានសរសេរជាអក្សរធំទាំងអស់ដែលមានលក្ខណៈខុសពីអក្សរសរសេរលើត្រាទាំង៧៣។ នៅកណ្តាលត្រាគ្មានរូបចតុកោណសម្រាប់កំណត់កាលបរិច្ឆេទតំកល់ទេ មានតែខ្សែរបន្ទាត់ត្រង់ពីរជាប់ជាមួយខ្សែរង្វង់ត្រាពីចុងម្ខាងទៅចុងម្ខាងប៉ុណ្ណោះ ដែលមានរូបភាពដូចខាងក្រោម៖





ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved




## ២/ផែនទី១២៦ផ្ទាំងផលិតដោយសេវាឥណ្ឌូចិននៅចន្លោះ១៩៣៣-១៩៥៣ ផ្តល់ដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង

ផែនទីបោនមាត្រដ្ឋាន១/១០០០០០ទាំង១២៦ផ្ទាំង របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ដែលផ្តល់ដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំងតាមអ៊ីម៉ែល សុទ្ធតែដូចគ្នាស្មើរតែតាំងស្រុងនឹងក្រុមផែនទីទទួលបានពីវិទ្យាស្ថានភូមិសាស្ត្របារាំងទាំង១១៩ផ្ទាំងដែរ។ អ្វីដែលធ្វើអោយចំនួនខុសគ្នា មកពីក្រុមផែនទី១២៦ របស់គណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំងមានផែនទីស្ទួនចំនួន៥ផ្ទាំង មាន៖ benglovea178W - Kampot226E- Moung175W- Siemreap167bisW - StengTreng162E ។ មានផែនទី៣ផ្ទាំងផ្សេងទៀត ដែលមិនមាននៅក្នុងក្រុម១១៩ នោះមាន៖ Attopeu147E - Dak-to148W - Phiafay146W តែក្រុមផែនទី១២៦ របស់គណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំងពុំមានផែនទី yali156E ទេ នៅពេលដែលក្រុមផែនទី១១៩ មានផែនទីខេត្ត yali ទាំងពីរផ្ទាំង yali156E និង yali156W។ ដូច្នេះធ្វើអោយចំនួនផែនទីខុសគ្នាតែពីរទេ រវាងផែនទីក្រុម ១២៦ និង១១៩។ ឯផែនទីផ្សេងទៀត សុទ្ធតែដូចគ្នាទាំងអស់។



ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

## ៣/ផែនទី៤៩ផ្ទាំង មាត្រដ្ឋាន១/១០០,០០០ ផ្តល់អោយដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង

ផែនទីមាត្រដ្ឋាន១/១០០,០០០ទាំង៤៩ផ្ទាំង (ខ្លះជាផែនទីបោននិងខ្លះជាផែនទីគ្មានខ្នាតត្រឹមត្រូវ) ត្រូវបានផ្តល់ដោយគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំនៅប្រទេសបារាំងតាមអ៊ីម៉ែល ថែមទាំងបានអះអាងថា ជាផែនទីត្រូវបានចុះបញ្ជីអង្គការសហប្រជាជាតិក្នុងទសវត្សទី៦០។ តាមការសិក្សាបឋម ផែនទីទាំងនេះ មួយចំនួនស្ថិតក្នុងកន្សោមផែនទីនៃសន្ធិសញ្ញាបំពេញបន្ថែម២០០៥។ ១៧ផ្ទាំងនៃផែនទីទាំង៤៩ ជាផែនទីបោនមាត្រដ្ឋាន ១/១០០០០០ ដូចផែនទីក្នុងក្រុម១១៩ដែរ ត្រូវបានផលិតនិងបោះពុម្ពដោយសេវាភូមិសាស្ត្រឥណ្ឌូចិន តែជាផែនទីនៃក្រុម៣៦ ដែលមានវាយត្រាចម្លែកឬត្រាក្លែងក្លាយ។ ក្នុងចំណើមផែនទី១៧ផ្ទាំង មានតែផែនទី១ផ្ទាំងទេ ដែលមិននៅក្នុងកន្សោមផែនទី១១៩ ជាផែនទីទាក់ទងនឹងខេត្តតាយនិញខាងកើត(tanh-ning210E) នេះប្រហែលអាចពន្យល់ពីការទាមទាររបស់រដ្ឋអំណាចភ្នំពេញអោយបក្សប្រឆាំងស្វែងរកផែនទី២ផ្ទាំងទៀតមកអោយខ្លួន គឺផែនទីតាយនិញខាងកើត (tanh-ning210E) និងដាក់តូខាងលិច(Dak-to148W) ។ ផែនទីតាយនិញខាងកើតនិងដាក់តូខាងលិច ពុំមាននៅក្នុងក្រុមផែនទី១១៩ទេ មានតែនៅក្នុងក្រុមផែនទី៤៩និង១២៦ ហើយមានតែភាគីយួនទេដែលមានផែនទីនេះ រួមទាំងផែនទីខ្មែរដ៏ទៃទៀតដែលផលិតនៅឆ្នាំក្រោយៗ ហើយដែលត្រូវបានយកទៅតំកល់នៅតាមស្ថាប័នអន្តរជាតិមួយចំនួនធំក្នុងពិភពលោក។ ផែនទី៣ផ្ទាំងទៀតនៃក្រុម៤៩ ជាប្រភេទផែនទីយោធាគឺ 154E 155W និង156W យកទៅតំកល់នៅវិទ្យាស្ថានជាតិបារាំងនៅថ្ងៃទី១៦មិថុនា១៩៦៤។

តារាងផែនទីទាំង២០នៃ៤៩(១៧ជាផែនទីបោន និង៣ជាផែនទីយោធា)

| | | | |
|---|---|---|---|
| 146E_Phiafay55-63 | 172E_Ko_Mayol52 | 201E_Loc_Ninh51 | 220E_Trang_Bang52 |
| 147W_Attopeu54-0 | 191E_Sre_Khtum52 | 210E_Tay_Ninh51 | 220W_Trang_Bang52 |
| 154E_Khong64army | 192E_Poste_Maitre53 | 218E_Takeo-fake | 226E_Kampot51 |
| 155W_Voeune_Sai64army | 192W_Poste_Maitre53 | 219E_Svay_Rieng28-50 | 227E_Ha_Tien |
| 156W_Ya_Li55-64army | 200W_Mimot51fake | 219W_Svay_Rieng51-83 | 227W_Ha_Tien |
| *តាយនិញ ជាផែនទីឥណ្ឌូចិនជាមួយនឹងត្រាចម្លែក ត្រូវបានគេបញ្ចូលក្នុងកន្សោមផែនទី៤៩ តែមិននៅក្នុងក្រុមផែនទី១១៩នៃ IGN ទេ | | | |

ក្រៅពីផែនទីទាំង២០ផ្ទាំងដូចរៀបរាប់ខាងលើ ផែនទី២៩ផ្ទាំងទៀតនៃក្រុម៤៩ ជាផែនទីមាត្រដ្ឋាន ១/១០០០០០ដែរ តែសុទ្ធសឹងជាផែនទីគូសដោយក្រុមអនាមិកនៅចន្លោះឆ្នាំ ១៩៧៧-១៩៨៨ ហើយត្រូវគេយកទៅតំកល់នៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងចន្លោះឆ្នាំ១៩៩៣-១៩៩៤។ ផែនទីទាំងនេះទាក់ទងនឹងខេត្ត៖ ១/កំពុងចាម ២/ក្រចេះ ៣/ស្វាយរៀង ៤/ព្រៃវែង ៥/កំពត ៦/ស្ទឹងត្រែង ៧/រតនៈគីរី ៨/មណ្ឌលគីរី ៩/កណ្តាល ១០/សៀមរាប និង១១/ព្រះវិហារ។ ផែនទីទាំង២៩ផ្ទាំងនេះ អាចជាផែនទីត្រូវបានគេរៀបចំសម្រាប់ការសើរើព្រំដែនកម្ពុជាជាថ្មីជាមួយប្រទេសជាតិខាង ជាពិសេសជាមួយប្រទេសយួន។ នៅក្នុងខ្លឹមសារនៃសន្ធិសញ្ញាបំពេញបន្ថែមក្នុងប្រការ២ យើងឃើញមានការរៀបរាប់ទាក់ទងតែខេត្ត៣ទេ មានខេត្ត រតនៈគីរី មណ្ឌលគីរី និងខេត្តកណ្តាលប៉ុណ្ណោះ ដែលគេបានប្រើប្រាស់ផែនទីបោនឥណ្ឌូចិន១/១០០០០០ចំនួន៥ផ្ទាំង Dakto 148W, Bokham164W, Komayon172-W, Bandon181-W និង Yaly156W ចម្លងលើផែនទីយោធាយូធីអិម១/៥០,០០០ ចំនួន៥ផ្ទាំង មាន


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

Phum Kham Dorang 6437-I ( ឧបសម្ព័ន្ធ១ ) PH. Thong 6436-I ( ឧបសម្ព័ន្ធ២ ) Ya Lop 3635-IV, Yok Mbre 6535-III, Merreuch 6435-II ( ឧបសម្ព័ន្ធ៣ )

តារាងផែនទីទាំង២៩៖

| | | | |
|---|---|---|---|
| C-48-8_Kampong_Cham81-94 | C-48-44_Prey_Veng81-93 | D-48-54-55_Preah_Vihear87-93 | D-48-96_Ratanakiri81-94 |
| C-48-9_Kampong_Cham81-94 | C-48-45_Svay_Rieng81-93 | D-48-57-56_Stung_Treng88-94 | D-48-107_Mondol_Kiri78-94 |
| C-48-10_Kratie81-94 | C-48-53_Kampot81-93 | D-48-59_Ratanakiri88-93 | D-48-108_Mondol_Kiri81-93 |
| C-48-20_Kampong_Cham81_93 | C-48-54_Kampot81-93 | D-48-60_Ratanakkiri81-93 | D-48-119_Mondol_Kiri77-94 |
| C-48-32_Prey_Veng81-94 | D-48-51_Siem_Reap77-94 | D-48-71_Ratanakiri81-93 | D-48-120_Mondol_Kiri81-93 |
| C-48-33_Svay_Rieng81-93 | D-48-52_Siem_Reap78-93 | D-48-83_Ratanakiri78-94 | D-48-132_Mondol_Kiri81-93 |
| C-48-43_Kandal81-93 | D-48-53_Preah_Vihear78-94 | D-48-84_Ratanakiri81-93 | D-48-142_Kratie81-93 |
| | | | D-48-143_Mondol_Kiri81-93 |

## ៤/ផែនទី២៦ផ្ទាំងដែលគណបក្សសង្គ្រោះជាតិ និងស្ថានទូតបារាំងយកទៅប្រគល់អោយរាជបណ្ឌិតសភា៖

ផែនទីបោនមាត្រដ្ឋាន១/១០០០០០ ២៦ផ្ទាំង ដែលគណបក្សសង្គ្រោះជាតិ និងស្ថានទូតបារាំងបានយកទៅប្រគល់អោយរដ្ឋាភិបាលភ្នំពេញ ដើម្បីយកទៅផ្ទៀងផ្ទាត់ជាមួយផែនទីរដ្ឋាភិបាលភ្នំពេញ ហើយដែលក្រសួងការបរទេសកម្ពុជា និងគណកម្មាធិការទទួលបន្ទុកខាងព្រំដែនបានអះអាងថា ដូចគ្នាបេះបិទនឹងផែនទីរបស់រដ្ឋាភិបាលភ្នំពេញ ក៏ដូចជាផែនទីផ្សេងៗទៀតដែលទទួលបានពីមជ្ឈដ្ឋាននានា ។ល។ គឺជាផែនទីដកចេញពីក្រុមផែនទី៣៦នៃកន្សោមផែនទី១១៩ដែលមានត្រាបោះត្រាចម្លែកឬត្រាក្លែងក្លាយ( ២៤ផ្ទាំង ) និង១ផ្ទាំងពីក្រុម១២៦ ( ដាក់តូខាងលិចDak-to148W ) ១ផ្ទាំងទៀតពីក្រុម៤៩( តាយនិញខាងកើត ( tanh-ning210E ) ។ ១ផ្ទាំងនៃផែនទី២៦ ជាផែនទីយោធាអាមេរិក( Yali156W55 ) ។

## តារាងផែនទីទាំង២៦

| | |
|---|---|
| 1.Dak To, 148-W, Ratanakiri | 14.Memot , 200-E, Kampong Cham |
| 2.Yali, 156 -W, Ratanakiri | 15.Memot , 200-W, Kampong Cham |
| 3.Bo Kham, 164-W, Ratanakiri | 16.Tay Ninh, 210-E, Kampong Cham |
| 4.Bo Kham, 164-E, Ratanakiri | 17.Tay Ninh, 210-W, Svay Rieng |
| 5.Ko Mayon, 172-E, Mondulkiri | 18.Prey Veng, 209-E, Prey Veng |
| 6.Ko Màyon, 172-W, Mondulkiri | 19.Trang Bang, 220-W, Svay Rieng |
| 7.Bandon, 181-W, Mondulkiri | 20.Trang Bang, 220-E, Svay Rieng |
| 8.Bandon, 181-E, Mondulkiri | 21.Svay Rieng, 219-E, Svay Rieng-Prey Veng |
| 9.Poste-Maitre, 192-E, Mondulkiri | 22.Svay Reing, 219-W, Prey Veng-Kandal |
| 10.Poste-Maitre, 192-W, Mondulkiri | 23.Takeo, 218-E, Kandal-Takeo |
| 11.Sre Khtum, 191-E, Mondulkiri | 24.Hatien, 227-E, Takeo |
| 12.Loc Ninh, 201-E, Kratie | 25.Hatien, 227-W, Takeo-Kampot |
| 13.Loc Ninh, 201-W, Kratie-Kampong Cham | 26.Kampot, 226-E, Kampot. |


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

## ៥/ផែនទីយោធាអាមេរិកយូធីអិមទាំង៤០ផ្ទាំងដែលភាគីយួន និងភាគីកម្ពុជាយកជាមូលដ្ឋានបោះបង្គោលរវាងកម្ពុជា-យួន

ផែនទីទាំង៤០ផ្ទាំង ជាប្រភេទផែនទីយូធីអិម មាត្រដ្ឋានដើមគឺ១/៥០,០០០ ដែលយោធាអាមេរិកគូសសម្រាប់ប្រើប្រាស់ទម្លាក់គ្រាប់បែកលើកម្ពុជា។ ផែនទីដើមត្រូវបានបោះពុម្ពដោយក្រសួងការពារជាតិអាមេរិក និងយោធាអាមេរិក (AMS ផែនទីជាផ្លូវការ) ឬដោយសហការជាមួយភ្នាក់ងារផែនទីជាតិអាមេរិក(DMA, NIMA NGIA) នៅចន្លោះឆ្នាំ ១៩៦៦-១៩៧១ តែផែនទីយូទីអិមដែលត្រូវបានគេយកមកប្រើប្រាស់ក្នុងសន្ធិសញ្ញាបំពេញបន្ថែម ២០០៥ មួយចំនួនធំជាផែនទីដែលគេសើរើនិង បោះពុម្ពជាថ្មីក្នុងចន្លោះឆ្នាំ១៩៩០-១៩៩៧ ដោយ DMA, NIMA NGIA ឬដោយភាគីយួនដូចជាផែនទី bon_drang_phok-6534-4 និង khum-trapeang-phlong6132_2 ជាដើម ។ល។ ផែនទីទាំង៤០គ្មានតម្លៃជាឯកសារផ្លូវការទេ ជាពិសេសផែនទីដែលបោះពុម្ពឡើងវិញដោយភាគីយួន ព្រោះផែនទីទាំងនោះត្រូវបានបោះត្រាប្លែកៗពីគ្នានិងមានប្រភពបោះពុម្ពផ្សេងៗគ្នា ហើយការសើរើមួយចំនួនលើផែនទីទាំងនោះគ្មានភាពស្របច្បាប់ជាឯកសារផ្លូវការឬមានការទទួលស្គាល់ដោយសហគមន៍អន្តរជាតិទេ។ លើសពីនេះទៅទៀត ផែនទីទាំង៤០ដែលបោះពុម្ពដោយ AMS DMA, NIMA NGIA ទោះជាផែនទីទើបនឹងសើរើឬបោះពុម្ពឡើងវិញនៅទសវត្សទី៩០ឬ២០០០ សុទ្ធតែមានចារថា ជាផែនទីមិនមានការ អនុញ្ញតឬមិនសម្រាប់បោះបង្គោលព្រំដែនអន្តរជាតិ ព្រោះសុទ្ធសឹងជាផែនទីមិនច្បាស់លាស់ ( សូមមើល ឧបសម្ព័ន្ធ១ Annex I) **ដូច្នេះកាលដែលយួនបង្ខំភាគីអាយ៉ងអោយទទួលរកផែនទីទាំងនោះសម្រាប់បោះបង្គោលព្រំដែនជាមួយភាគីយួន វាជាការរំលោភអធិបតេយ្យបូរណភាពទឹកដីមិនអាចរំលោភបានរបស់កម្ពុជា ក៏ដូចជាការរំលោភច្បាប់អន្តរជាតិដែរ។**

ផែនទីយូធីអិមទាំង៤០ ដែលភាគីយួននិងភាគីកម្ពុជាអះអាងថា មានមូលដ្ឋានភូមិសាស្ត្រដូចគ្នានឹងផែនទីបោន ១/១០០.០០០ ទាំង២៦ផ្ទាំងរបស់សេវាឥណ្ឌូចិន ជាផែនទីដែលដែលខ្សែបន្ទាត់ព្រំដែនមួយចំនួនត្រូវបានគូសឡើងវិញតាមអ្វីដែលគេកំណត់ក្នុងសន្ធិសញ្ញាព្រំដែន១៩៨៥ និងបញ្ជាក់ឡើងវិញក្នុងសន្ធិសញ្ញាបំពេញបន្ថែម ២០០៥។ នេះជាហេតុផលមួយដែលធ្វើអោយពលរដ្ឋខ្មែររស់នៅតាមបណ្តោយព្រំដែនខ្មែរ-យួន ត្រូវបាត់បង់ទឹកដីរបស់ពួកគាត់ដែលរស់នៅតាំងតែពីដូនតាមក ដោយព្រោះតែផែនទីយកមកប្រើប្រាស់មិនច្បាស់លាស់ និងមានការគូសខ្សែព្រំដែនថ្មីលើផែនទីទាំងនោះមួយចំនួនថែមទៀត។ អ្វីដែលគួរអោយបារម្មណ៍សម្រាប់កម្ពុជាទៅថ្ងៃអនាគតនោះគឺ មិនត្រឹមតែផែនទីបោនមាត្រដ្ឋាន ១/១០០០០០ របស់កម្ពុជានៅវិទ្យាស្ថានជាតិបារាំងទេដែលត្រូវបានគេលួចប្តូរហើយជំនួសដោយផែនទីក្លែងក្លាយនិងផែនទីដែលទើបនឹងគូសថ្មី តែសូម្បីផែនទីយោធាអាមេរិកមួយចំនួនក៏ត្រូវបានសើរើនិងគូសឡើងវិញ ហើយត្រូវបានបញ្ជូនទៅរក្សាទុកតាមស្ថាប័នអន្តរជាតិនានាដោយភាគីកម្ពុជាពុំបានដឹង។



ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

## តារាងផែនទីយូធីអិមទាំង៤០ផ្ទាំង

| | |
|---|---|
| 1.Dak Mot Lop, 6538 –III, 1966 | 21.Loc Ninh, 6332-IV, 1968 |
| 2.Polei Jar Sieng, 6537-IV, 1966 | 22.Choam Kravien, 6232-I, 1971 |
| 3.Phum Kham Dorang, 6437 -I, 1966 | 23.Bo Tuc, 6232-II, 1966 |
| 4.Phum Hay, 6437-II, 1970 | 24.Ta Dath, 6232-III, 1968 |
| 5.Phum Thong, 6436-I, 1966 | 25.Me Mut, 6232-IV, 1971 |
| 6.Le Thanh, 6536-IV, 1966 | 26.Khum Tranpeang Phlong, 6132-II, 1966 |
| 7.Pl. Ya Bo, 6536-III, 1966 | 27.Phum Kampong Trach 6131-I, 1970 |
| 8.Ya Lop, 6535-IV, 1966 | 28.Svay Rieng, 6131-II, 1970 |
| 9.Yok Mbre, 6535-III, 1966 | 29.An Thanh, 6231-III, 1969 |
| 10.Mereuch, 6435-II, 1966 | 30.Duc Hue, 6230-IV, 1966 |
| 11.O Tea, 6434-I, 1966 | 31.Moc Hoa, 6130-I, 1966 |
| 12.Bon Drang Phok, 6534-IV, 1966 | 32.Prey Nhay, 6131-III, 1966 |
| 13.Bon Dak N'Drot, 6534-III, 1966 | 33.Vinh Thang, 6130-IV, 1966 |
| 14.Duc Minh, 6533-IV, 1966 | 34.Hong Gnu, 6030-I, 1966 |
| 15.Dak Dam, 6433-I, 1966 | 35.Tan Chau, 6030-IV, 1966 |
| 16.Ap Doan Van, 6433-II, 1966 | 36.Chau Phu, 6030-III, 1970 |
| 17.O Rang, 6433-IV, 1966 | 37.Tinh Bien, 5930-II, 1971 |
| 18.Bu Gia Map, 6433-III, 1966 | 38.Tuk Meas, 5930-III, 1971 |
| 19.Ap Phuoc Thien, 6333-II, 1971 | 39.Kien Luong, 5929-IV, 1966 |
| 20-Meak Say 6333-III | 40.Krong Kep, 5829-I, 1966 |

ដោយយោងតាមរបាយការណ៍និងភស្តុតាងខាងលើ បញ្ជាក់អោយឃើញថា ការបោះបង្គោលព្រំដែនខ្មែរ-យួន ចុងក្រោយរវាងភ្នំពេញនិងហាណូយ មិនអាចយកជាការបានទេ ព្រោះវាបានរំលោភលើច្បាប់ជាតិនិងអន្តរជាតិ សម្រាប់ការកំណត់ព្រំដែនកម្ពុជានិងយួន ហើយសកម្មភាពនេះត្រូវតែបញ្ឈប់ជាបន្ទាន់រហូតទាល់តែផែនទីពិតដែលត្រូវបាត់បង់ត្រូវរកឃើញ ហើយការបោះបង្គោលណាមួយត្រូវតែធ្វើឡើងលើមូលដ្ឋានបង្គោលចាស់ទាំង១២៤របស់អាណានិគមន៍បារាំង។ ពលរដ្ឋខ្មែរក៏ចង់អោយមានការពន្យល់បកស្រាយជុំវិញបញ្ហាក្លែងបន្លំផែនទី និងផែនទីនៃការសើរើខ្សែបន្ទាត់ព្រំដែនកម្ពុជា ដែលទើបតែត្រូវបានគេបញ្ជូនទៅរក្សាទុកនៅតាមស្ថាប័នអន្តរជាតិនានា។ យើងសូមអំពាវនាវដល់រដ្ឋាភិបាលអោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតលើការលួចបន្លំផែនទីនិងប្តូរផែនទីរបស់ខ្មែរដោយភាគីណាមួយដើម្បីបោកប្រាស់និងកេងចំណេញទឹកដី។ បើគ្មានការប្តូរបន្លំផែនទីទេ ផែនទីទាំង១១៩ផ្ទាំងដែលត្រូវបានយកទៅតំកល់នៅវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំងត្រូវមានបោះត្រា កំណត់បរិច្ឆេទយកទៅតំកល់ដូចៗគ្នាគឺថ្ងៃទី៥ធ្នូ១៩៦៣ ទាំង១១៩ផ្ទាំង។ បើការបោះបង្គោលព្រំដែនប្រើប្រាស់ផែនទីត្រឹមត្រូវ ពលរដ្ឋរស់នៅតាមបណ្តោយព្រំដែនខ្មែរ-យួន ក៏មិនត្រូវបាត់បង់ទឹកដីជូនតាពួកគេលើសពីអ្វីដែលបារាំងកាត់ទៅអោយយួនដែរ។ លើសពីនេះទៅទៀត តាមច្បាប់អន្តរជាតិ ប្រទេសបារាំងក្នុងនាមជាអាណានិគមន៍ គ្មានសិទ្ធិណាមួយកាត់ទឹកដីកម្ពុជាក្រោមនិងកោះត្រល់ទៅអោយយួនឡើយ ហើយទោះជាដូច្នោះក្តីសកម្មភាពខុសច្បាប់អន្តរជាតិទាំងនេះត្រូវបានចាត់ទុកជាមោឃៈដោយ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២៣តុលា១៩៩១។ ដូច្នេះតាមច្បាប់អន្តរជាតិនិងតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស១៩៩១ ប្រទេសយួនត្រូវតែប្រគល់កោះត្រល់និងទឹកដីកម្ពុជាក្រោមមកអោយខ្មែរវិញ។

យើងក៏សង្កេតឃើញថា ឆាកល្ខោនផ្ទៀងផ្ទាត់ផែនទីរវាងបក្សកាន់អំណាចនិងបក្សជាដៃគូ គឺគ្មានទិសដៅអ្វីផ្សេងក្រៅ



ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

ពីសុំគ្រលុំជាមួយបក្សកាន់អំណាចដើម្បីបំភាន់មតិជាតិនិងអន្តរជាតិថា បក្សកាន់អំណាចនិងភាគីយួនបានប្រើប្រាស់ផែនទីត្រឹមត្រូវតាមច្បាប់ជាតិនិងអន្តរជាតិ ហើយយួនមិនបានរំលោភបំពានលើបូរណភាពទឹកដីមិនអាចរំលោភបានរបស់កម្ពុជាទេ និង ជាពិសេសគេព្យាយាមរកយុទ្ធសាស្ត្រដើម្បីឈានដល់ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា២។ វិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា២ ជាហានិភ័យនិង ជាគ្រោះថ្នាក់ដ៏ធំធេងដល់កម្ពុជា ព្រោះជាការ បើកផ្លូវចំហរអោយបក្សកាន់អំណាចនិងភាគីពាក់ព័ន្ធប្រើប្រាស់ផែនទីជាច្រើនទៀតដែលពួកគេទើបតែគូសវាសដើម្បី រំលោភទន្ទ្រានយកទឹកដីកម្ពុជាដោយស្របច្បាប់ទៅថ្ងៃអនាគត។

ក្នុងលិខិត្រមួយផ្ញើទៅប្រធានាធិបតីនៃសាធារណៈរដ្ឋបារាំង លោក ហ្វ្រង់ស័រហូឡង់កាលពីថ្ងៃទី១កញ្ញា២០១៥ នេះ លោកហ៊ុនសែនបានបញ្ជាក់ថា រដ្ឋាភិបាលភ្នំពេញនិងហាណូយ បានបោះបង្គោលព្រំដែនដោយយកតាមសន្ធិសញ្ញា១៩៨៥ បញ្ជាក់ឡើងវិញតាមសន្ធិសញ្ញា២០០៥ ដែលជាសន្ធិសញ្ញាខុសច្បាប់ ចុះហត្ថលេខាជាមួយប្រទេសយួននៅឆ្នាំ១៩៨៥។ សន្ធិសញ្ញាខុសច្បាប់នេះ ព្រមទាំងសន្ធិសញ្ញាខុសច្បាប់ដ៏ទៃទៀត បានត្រូវទុកជាមោឃៈទៅហើយដោយកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស២៣តុលា១៩៩១។ ការយកសន្ធិសញ្ញាខុសច្បាប់នេះនេះមកប្រើប្រាស់ឡើងវិញ គឺជាការរំលោភបំពានដល់អធិបតេយ្យនិងបូរណភាពទឹកដីមិនអាចរំលោភបានរបស់កម្ពុជាដោយប្រទេសយួន ហើយក៏ជាការរំលោភធ្ងន់ធ្ងរដល់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២៣តុលា១៩៩១ ដែលយួនជាម្ចាស់ហត្ថលេខីដ៏សំខាន់មួយ។ ការរំលោភដោយកំរោលនិងដោយប្រហើនកោងកាចនេះ ធ្វើអោយពលរដ្ឋខ្មែររស់នៅតាមព្រំដែនជាច្រើនរយគ្រួសារបាត់បង់ទឹកដីកេរ្តិ៍មរតកដូនតារបស់គេ និងមធ្យោបាយរស់នៅរបស់គេ បន្ថែមលើពលរដ្ឋខ្មែរជាង៨៣០,០០០ នាក់ទៀត (តាមរបាយការណ៍ថ្មីរបស់លោករីឆាត-រ៉ូធើប្ដឹងទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ដែលកំពុងប្រឈមនឹងការបាត់បង់ទឹកដីដូនតាខ្លួនដោយសារនយោបាយសប្បទានសេដ្ឋកិច្ចរបស់រដ្ឋអំណាចភ្នំពេញ ដែលគ្មានអ្វីក្រៅពីរបៀបយកដីពលរដ្ឋម្ចាស់ស្រុកតាមបែបអាណានិគមន៍បែបថ្មី។ ការឈ្លានពាននិងរំលោភបំពាននេះ ទាមទារអោយមានអន្តរាគមន៍របស់សហគមន៍អន្តរជាតិដើម្បីបញ្ចប់ការឈ្លានពានរបស់ប្រទេសយួននិងប្រទេសផ្សេងៗទៀតមកលើកម្ពុជា។

ថ្ងៃទី ២៣ កញ្ញា២០១៥
ខ្មែរឯនាយសមុទ្រ ក.ស.ឯ


ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved

# ឧបសម្ព័ន្ធ (II)

១/ បញ្ជីផែនទីបោនមាត្រដ្ឋាន១/១០០០០០ ៦៩ផ្ទាំងនៃផែនទី១១៩ របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ដែលមានបោះត្រាតំកល់ ៥ធ្នូ១៩៦៣ ។

២/ បញ្ជីផែនទីយោធាអាមេរិកកាំងទាំ៤ផ្ទាំង នៃផែនទី១១៩ របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ដែលមានបោះត្រាតំកល់ ថ្ងៃទី១៦មិថុនា១៩៦៤ ។

៣/ បញ្ជីផែនទីបោនមាត្រដ្ឋាន១/១០០០០០ ៣៦ផ្ទាំងនៃផែនទី១១៩ របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ដែលមានបោះត្រាចម្លែក

៤/ បញ្ជីផែនទីបោនមាត្រដ្ឋាន១/១០០០០០ ១០ផ្ទាំងនៃផែនទី១១៩ របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ដែលគ្មានត្រា

៥/ បញ្ជីផែនទីបោនមាត្រដ្ឋាន១/១០០០០០ ២៦ផ្ទាំង របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង ប្រើប្រាស់ដោយរដ្ឋាភិបាល ភ្នំពេញដើម្បីផ្ទៀងផ្ទាត់ផែនទីផ្សេងៗ។

៦/ បញ្ជីផែនទីកំណត់ព្រំដែននិងតម្រុយព្រំដែនចាស់ក្នុងនិក្ខេបទលោកសារិនចាក

៧/ បញ្ជីផែនទីបោនមាត្រដ្ឋាន១/១០០០០០ ១៧ផ្ទាំងនិងផែនទីយោធា៣ផ្ទាំង នៃកន្សោមផែនទី៤៩ របស់វិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង

៨/ បញ្ជីផែនទី១/១០០០០០ ២៩ផ្ទាំងនៃកន្សោមផែនទី៤៩ ដែលទើបតែគូសឡើងវិញនៅចន្លោះឆ្នាំ១៩៧៧-១៩៨៨ និងយកទៅតំកល់នៅវិទ្យាស្ថានជាតិបារាំងនៅឆ្នាំ១៩៩៣-១៩៩៤

៩/ បញ្ជីផែនទីUTMខ្នាត១/៥០០០០ទាំង៤០ប្រើប្រាស់ក្នុងសន្ធិសញ្ញា១៩៨៥ឬសន្ធិសញ្ញាបំពេញបន្ថែម២០០៥

បន្ថែម៖ សូមបញ្ជាក់ថា ក.ស.ឯ. មានផែនទីទាំងអស់ដែលរៀបរាប់ខាងលើ បើចង់បានផែនទីទាំងនោះ សូមទាក់ទងមកយើងតាមរយៈអីម៉ែល ចុចដោនឡោតពីទំព័រនេះ៖

http://tdc.kh.free.fr/crutial-event/in-khmaps-IRScom.htm



ក.ស.ឯ. រក្សាសិទ្ធគ្រប់យ៉ាង @All rights reserved